**Alert.seattle.gov/volcano** (ការជូនដំណឹង.seattle.រដ្ឋាភិបាល/បន្ទុះភ្នំភ្លើង)

**ការណ៍ពិត ៖** ភ្នំភ្លើងបានផ្ទុះឡើង នៅរដ្ឋវ៉ាស៊ីនតោន ។ គ្រោះថ្នាក់បន្ទុះភ្នំភ្លើង រួមមាន ផេះ ថ្ម កម្អែភ្នំភ្លើង លំហូរភក់ និងស្រទាប់ដីបាក់ ដែលមានសីតុណ្ហភាពក្តៅ ។ បន្ទុះភ្នំភ្លើង អាចបង្ករ ការខូចខាតធ្ងន់ធ្ងរ ដល់ផ្លូវថ្នល់ អគ្គិសនី ទឹក សេវាបម្រើបម្រាស់នានា ហើយបង្ករឱ្យមានគ្រោះថ្នាក់ ដល់សុខភាព ក្នុង
រយៈចម្ងាយរាប់រយម៉ាយ តាមកម្លាំងខ្យល់បក់ ដោយវាបក់នាំពពកផេះហុត់យកទៅ ជាមួយ ។

**អ្វីដែលត្រូវធ្វើ ៖**

- លោកអ្នកអាចត្រូវបានស្នើសុំឱ្យជ្រកនៅនឹងកន្លែង ឬជម្លៀសចេញពីទីកន្លែង ។ ត្រៀមលក្ខណៈជាស្រេច ដើម្បីចាត់វិធានការណាមួយ ក្នុងចំណោមជម្រើសទាំងពីរ ។
- ប្រសិនបើមានការប្រាប់ឱ្យជ្រកនៅនឹងកន្លែង សូមត្រៀមលក្ខណៈស្នាក់នៅខាងក្នុងផ្ទះ ។ នាំក្រុមគ្រួសារ និងសត្វចិញ្ចឹមរបស់លោកអ្នក ឱ្យនៅ ក្នុងផ្ទះ ។ បិទទ្វារ បង្អួច និងឡដុតកំដៅ ហើយចាក់សោ ។ ដាក់កន្សែងពោះគោសើម នៅច្រកទ្វារ ចូល និងច្រកផ្សេងៗ ទៀត ដែលអាចឱ្យកំសួលពីខាងក្រៅ ចូលបាន ។
- បិទកង្ហារ ម៉ាស៊ីនត្រជាក់ ប្រព័ន្ធកំដៅ និងប្រព័ន្ធផ្សេងទៀត ដែលបូមខ្យល់ពីខាងក្រៅ ។
- ត្រៀមលក្ខណៈ នឹងធ្វើការកែច្នៃ ហើយប្រើអ្វីដែលលោកអ្នកមាននៅក្នុងដៃ ដើម្បីបិទរន្ធចន្លោះ ដើម្បីបិទបាំងខ្លួនលោកអ្នក ពីខ្យល់ខាងក្រៅ ។
- ការពារសួតរបស់លោកអ្នក ដោយពាក់ម៉ាស់មុខ ដែលអាចបោះចោលបាន ។ ប្រសិនបើ លោកអ្នកមានបញ្ហាផ្លូវដង្ហើម អនុវត្តតាមផែនការគ្រប់គ្រងជំងឺហឺតរបស់លោកអ្នក ។
- ការពារភ្នែករបស់លោកអ្នក ដោយដោះកែវដាក់ភ្នែកចេញ (contact lenses) ហើយពាក់វ៉ែនតា ឬ វ៉ែនតាការពារភ្នែក (protective goggles) ជំនួសវិញ ។
- ប្រសិនបើមានការប្រាប់ឱ្យជម្លៀសចេញ សូមធ្វើតាមភ្លាម ។ ទៅតាមផ្លូវដែលបាន ណែនាំប្រាប់ ដូចមានផ្តល់ជូននៅក្នុងសេចក្តីជូនដំណឹងអំពីការជម្លៀសចេញ ។ ផ្លូវមួយចំនួន អាចមានផ្លាកសញ្ញា ដាក់នៅតាមបណ្តោយផ្លូវ និងវិថីធំៗ ។

- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។
- *ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮ អំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។*

តំណរបណ្តាញដែលមានប្រយោជន៍ ៖

http://www.seattle.gov/emergency-management/what-if/hazards/volcano-hazards-including-lahars

http://mil.wa.gov/emergency-management-division/hazards/volcano

http://www.ready.gov/volcanoes